# សេចក្ដីជូនដំណឹង

# ស្ដីពី

# ការបញ្ជាក់ជាថ្មីនូវចំណាត់ថ្នាក់ ឥណទានរបស់ធនាគារ ABA នៅកម្រិត ' B+' ជាមួយទស្សនៈ វិស័យស្ថិរភាព ដោយភ្នាក់ងារវាយតម្លៃ Standard & Poor's Global

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (ធនាគារ ABA) សូមប្រកាសថានាថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២១នេះ ភ្នាក់ងារវាយតម្លៃ Standard & Poor's Global (S&P) បានបញ្ជាក់ជាថ្មីអំពីចំណាត់ថ្នាក់ឥណទានរបស់ធនាគារ ABA នៅកម្រិត 'B+' ជាមួយទស្សនវិស័យស្ថិរភាព។

ទស្សនៈវិស័យស្ថិរភាពឆ្លុះបញ្ចាំងពីទស្សនៈរបស់ S&P ដែលថា ធនាគារនឹងគ្រប់គ្រងប្រកបដោយចីរភាពនូវកំណើនយ៉ាងឆាប់រហ័សនៃប្រាក់កម្ចី និងប្រាក់បញ្ញើ ខណៈដែលប្រទេសកំពុងងើបឡើងពីការរីករាលដាលនៃ វីរុសកូវីដ-19។ អ្នកជំនាញរបស់ S&P ក៏បានបញ្ចេញទស្សនៈថា កម្មវិធីឌីជីថលរបស់ធនាគារ ABA គឺជា អត្ថប្រយោជន៍ប្រកួតប្រជែងដែលគាំទ្រកំណើនប្រាក់កម្ចី និងប្រាក់បញ្ញើ។ ធនាគារ ABA ក៏បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហានិភ័យដែលមានលក្ខណៈទំនើបជាងមុន ជាមួយនឹងការវិភាគលំហូរសាច់ប្រាក់ ដើម្បីគាំទ្រលើការសម្រេចចិត្តឥណទានបើធៀបជាមួយនឹងដៃគូក្នុងស្រុក។

យោងតាមរបាយការណ៍របស់ S&P និមិត្តសញ្ញាអាជីវកម្មរបស់ធនាគារ ABA កំពុងតែមានភាពរឹងមាំ ដោយសារតែកំណើនដ៏គួរកត់សម្គាល់នៃចំណែកទីផ្សារ ក្នុងទម្រង់នៃប្រាក់កម្ចី និងប្រាក់បញ្ញើ បណ្ដាញចែកចាយរូបវន្ត និងឌីជីថល ព្រមទាំងមូលដ្ឋានអតិថិជនរបស់ខ្លួន។ ជាមួយប្រសិទ្ធភាពប្រតិបត្តិការដ៏ល្អ កត្តាទាំងនេះគាំទ្រដល់ប្រាក់ចំណេញដ៏ប្រសើររបស់ធនាគារ។ អ្នកជំនាញរបស់ S&P ក៍បានពិនិត្យលើការគ្រប់គ្រងដែលមានជំនាញ សមត្ថភាព និងភាពបត់បែនក្នុងការស្វែងរកលក្ខខណ្ឌប្រតិបត្តិការដែលងាយ ក្នុងអំឡុងពេលនៃជំងឺរាតត្បាតនៃវីរុសកូវីដ-19 ហើយជឿជាក់ថាការត្រួតពិនិត្យពីធនាគារជាតិនៃកាណាដារួមទាំងក្រុមប្រឹក្សាភិបាល និងក្រុមសវនកម្ម របស់ធនាគារ ABA គឺគាំទ្រដល់ការសម្រេចចិត្តលើហានិភ័យនៅ ធនាគារ ABA។

អ្នកជំនាញរបស់ S&P បានមានលើកឡើងអំពីស្ថានភាពអាជីវកម្មដ៏មានស្ថិរភាព និងសក្ដានុពលរបស់ធនាគារ ABA សម្រាប់កំណើនបន្ថែមទៀតថា៖ "មូលដ្ឋានប្រាក់បញ្ញើរបស់អតិថិជនដ៏ធំនឹងបន្តកើនឡើងយ៉ាងហោចណាស់ ស្របជាមួយនឹងប្រាក់កម្ចីរបស់ធនាគារ ដោយសារកម្មវិធីឌីជីថលដ៏រឹងមាំរបស់ខ្លួន។ និមិត្តសញ្ញាអាជីវកម្ម មូលធននីយកម្ម ទម្រង់ហានិភ័យ ការផ្ដល់មូលនិធិ និងសាច់ប្រាក់ងាយស្រួលដែលជាមូលដ្ឋានរបស់ធនាគារ ABA នឹងនៅតែមានស្ថេរភាពយ៉ាងទូលំទូលាយក្នុងរយៈពេល ១២-១៨ ខែបន្ទាប់។"

ភ្នាក់ងារវាយតម្លៃអន្តរជាតិ S&P បានផ្ដល់ចំណាត់ថ្នាក់ឥណទានកម្រិត 'B' ដល់ធនាគារ ABA នៅក្នុងឆ្នាំ ២០១៧។ ចំណាត់ថ្នាក់នេះត្រូវបានដំឡើងដល់កម្រិត 'B+' នៅឆ្នាំ ២០១៩ ផ្អែកលើកំណើននូវចំណែកទីផ្សារដែលកំពុងកើនឡើងដ៏សំខាន់នៃប្រាក់កម្ចី និងប្រាក់បញ្ញើ រួមនឹងការទទួលបានប្រាក់ចំណេញលើសពីមធ្យម។

ABA BANK
NATIONAL BANK OF CANADA GROUP
25 YEARS

Head Office

No 141, 146, 148, and 148ABCD, Preah Sihanouk Blvd, and
No 15 and 153ABC, Street 278, Sangkat Boeung Keng Kang I,
Khan Boeung Keng Kang, Phnom Penh, Kingdom of Cambodia

Tel: (+855) 23 225 333
info@ababank.com
www.ababank.com

Fax: (+855) 23 216 333
P.O. Box: 2277
SWIFT: ABAAKHPP

ថ្ងៃព្រហស្បតិ៍ ៥កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១
**ធនាគារវឌ្ឍនៈអាស៊ី ចំកាត់**

ABA BANK
NATIONAL BANK OF CANADA GROUP
25 YEARS

**Head Office**

No 141, 146, 148, and 148ABCD, Preah Sihanouk Blvd, and
No 15 and 153ABC, Street 278, Sangkat Boeung Keng Kang I,
Khan Boeung Keng Kang, Phnom Penh, Kingdom of Cambodia

Tel: (+855) 23 225 333
info@ababank.com
www.ababank.com

Fax: (+855) 23 216 333
P.O. Box: 2277
SWIFT: ABAAKHPP